01311272

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de recep on): 05 / 08 / 2016
ម៉ោង (Time/Heure) : 14 : 45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E315/1/6/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៦

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**
**អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU)**
**ការិយាល័យរដ្ឋបាល**

**កម្មវត្ថុ÷** **សេចក្តីបង្គាប់នៅលើការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1049**

១. នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈអ៊ីម៉ែលពីមន្ត្រីច្បាប់ថា សវនាការស្តីពីព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង សម្រាប់អង្គហេតុមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ត្រូវបានគ្រោងធ្វើរយៈពេល ០២ ថ្ងៃ។ នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានបញ្ជាក់តាមរយៈអ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ថា សវនាការនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១១ និងថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦។

២. នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ សហមេធាវីនាំមុខបានដាក់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្ប-

វេណីដែលត្រូវបានជ្រើសរើស ហើយបានស្នើសុំស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីម្នាក់តាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង (ឯកសារ E315/1/6; ឯកសារE316/1/6.1; *សូមមើលផងដែរ* ឯកសារ E3/5040)។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រូវបានកំណត់ឱ្យផ្តល់សក្ខីកម្មរយៈពេល ៨៥ នាទី។ អង្គជំនុំជម្រះសូមរម្លឹកថា អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការសម្រេចថា តើគួរស្តាប់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ឬ យ៉ាងណា។ ក្នុងករណីនេះ ដោយសារតែគាត់មានវ័យចាស់ជរាផងនោះ អង្គជំនុំជម្រះយល់ឃើញថា មិនចាំបាច់តម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើដំណើរពីប្រទេសបារាំងមកប្រទេសកម្ពុជា ដើម្បីធ្វើសេចក្តីថ្លែងពីទុក្ខសោកវេទនានោះទេ ដោយហេតុថាមានមធ្យោបាយផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍។ ហេតុនេះ អង្គជំនុំជម្រះបង្គាប់ឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជួយសម្រួលឱ្យដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1049 ផ្តល់សក្ខីកម្មស្តីពីព្យសនកម្មដែលគាត់បានទទួលរង តាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង។ អង្គជំនុំជម្រះបង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ រៀបចំមធ្យោបាយទាំងអស់ដែលចាំបាច់ ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីរៀបចំស្តាប់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅថ្ងៃ ព្រហស្បតិ៍ ទី ១១ ខែ សីហា ឆ្នាំ ២០១៦។